ធ៧-០៦-២០៩ ប្រ.ក

# ប្រកាស
# ស្ដីពី
# ការកែសម្រួលប្រកាសស្ដីពី
# ការផ្ដល់អាជ្ញាប័ណ្ណចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

ធ្វើវិសោធនកម្មដោយប្រកាសលេខ ធ៧-០១៣-១២២ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៣ ស្ដីពី ការកំណត់សោហ៊ុយសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។

**ប្រការ ១.-**

កែសម្រួលប្រការ ៩ និងប្រការ ១៣ នៃប្រកាសលេខ ធ៧-០០-០៦ប្រក ចុះថ្ងៃទី១១ ខែមករា ឆ្នាំ ២០០០ ស្ដីពី ការផ្ដល់អាជ្ញាប័ណ្ណចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ មានដូចខាងក្រោម៖

សូមអានប្រការ ៩ និង ១៣ថ្មី នៃប្រកាសលេខ ធ៧-០០-០៦ ប្រក ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០០។

**ប្រការ ២.-**

ត្រូវជំនួសដោយប្រការ ៨ ចំណុច ឃ នៃប្រកាសលេខ ធ៧-០១៣-១២២ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៣ ស្ដីពីការកំណត់សោហ៊ុយសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

**ប្រការ ៣.-**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន អង្គភាព គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទនិងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ៤.-**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០៦

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**